# ឥសិគិលិបរិត្ត (ឆមិឥសិគិលី)

## (បិដក និង អដ្ឋកថា)



ដកស្រង់រៀបរៀងដោយភិក្ខុ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្តីផ្តើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្តីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្តីសុខ សេចក្តីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្តីសុខ សេចក្តីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

*វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី២២ ខែមេសាឆ្នាំ២០២៣*

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

# ឥសិគិលិបរិត្ត

(បិដកលេខ ២៦ ទំព័រ ៣២៨)

**ឯវម្មេ សុតំ** សូត្រនេះ (ឈ្មោះឥសិគិលិសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា

**ឯកំ សមយំ ភគវា រាជគហេ វិហរតិ ឥសិគិលិស្មឹ បព្វតេ** សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅលើភ្នំឥសិគិលិទៀបក្រុងរាជគ្រឹះ ។

**តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅនូវភិក្ខុទាំងឡាយក្នុងទីនោះដូច្នេះថា **ភិក្ខវោ** ម្នាលភិក្ខុទាំងឡាយ ។

**ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទាំងឡាយនោះ ក៏ទទួលឆ្លើយតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគដូច្នេះថា **ភទន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ។

**ភគវា ឯតទវោច** ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងនូវឥសិគិលិសូត្រនេះ ដោយព្រះពុទ្ធដីដូច្នេះថា

**បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ វេភារំ បព្វតន្តិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំវេភារៈនុ៎ះឬទេ

**ឯវំ ភន្តេ** ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា **ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

**ឯតស្ស ខោ**[១] **ភិក្ខវេ វេភារស្ស បព្វតស្ស អញ្ញា ច សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ** ម្នាលភិក្ខុទាំងឡាយ ភ្នំវេភារៈនុ៎ះឯង មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេង ។

**បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ បណ្ឌវំ បព្វតន្តិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំបណ្ឌវៈនុ៎ះឬទេ

**ឯវំ ភន្តេ** ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា **ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

**ឯតស្ស ខោ**[២] **ភិក្ខវេ បណ្ឌវស្ស បព្វតស្ស អញ្ញាច សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ** ម្នាលភិក្ខុទាំងឡាយ ភ្នំបណ្ឌវៈនុ៎ះឯង ក៏មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេងដែរ ។

**បស្សថ នោ តុម្ហេភិក្ខវេ ឯតំ វេបុល្លំ បព្វតន្តិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំវេបុល្លៈនុ៎ះឬទេ

**ឯវំ ភន្តេ** ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា **ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

**ឯតស្ស ខោ**[៣] **ភិក្ខវេ វេបុល្លស្ស បព្វតស្ស អញ្ញាច សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ** ម្នាលភិក្ខុទាំងឡាយ ភ្នំវេបុល្លៈនុ៎ះឯង មានឈ្មោះ

ផ្សេង មានបញ្ញត្តិផ្សេងដែរ ។

**បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ គិជ្ឈកូដំ បព្វតន្តិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំគិជ្ឈកូដនេះឬទេ

**ឯវំ ភន្តេ** ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

**ឯតស្ស ខោ ភិក្ខវេ គិជ្ឈកូដស្ស បព្វតស្ស អញ្ញាវ សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ** ម្នាលភិក្ខុទាំងឡាយ ភ្នំគិជ្ឈកូដនុ៎ះឯង មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេងដែរ ។

**បស្សថ នោ តុម្ហេ ភិក្ខវេ ឥមំ ឥសិគិលឹ បព្វតន្តិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំឥសិគិលិនេះឬទេ

**ឯវំ ភន្តេ** ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។

**ឥមស្ស ខោ បន ភិក្ខវេ ឥសិគិលិស្ស បព្វតស្ស ឯសា វ សមញ្ញា អហោសិ ឯសា បញ្ញត្តិ** ម្នាលភិក្ខុទាំងឡាយ ឯភ្នំឥសិគិលិនេះឯង មានឈ្មោះយ៉ាងហ្នឹង មានបញ្ញត្តិយ៉ាងហ្នឹងតែម្យ៉ាង ។

**ភូតបុព្វំ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងពីព្រេងនាយមកថា

**បញ្ច បច្ចេកពុទ្ធសតានិ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសិនោ អហេសុំ** មានព្រះបច្ចេកពុទ្ធ ៥០០ អង្គ នៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។

**តេ ឥមំ បព្វតំ បវិសន្តា ទិស្សន្តិ បវិដ្ឋា ន ទិស្សន្តិ** ព្រះបច្ចេកពុទ្ធ

ទាំងឡាយនោះ កាលចូលទៅកាន់ភ្នំនេះ មនុស្សទាំងឡាយឃើញប្រាកដ លុះចូលស៊ប់ទៅហើយ មនុស្សទាំងឡាយមិនឃើញឡើយ ។

**តមេនំ មនុស្សា ទិស្វា ឯវមាហំសុ** លុះមនុស្សទាំងឡាយ បានឃើញនូវហេតុនោះហើយ ក៏នាំគ្នានិយាយយ៉ាងនេះថា

**អយំ បព្វតោ ឥមេ ឥសី គិលតីតិ ឥសិគិលិ ឥសិគិលិ ត្វេវ សមញ្ញា ឧទបាទិ** ភ្នំនេះលេបនូវឥសីទាំងឡាយនេះ ព្រោះហេតុនោះ បានជាមានឈ្មោះកើតឡើងថា ឥសិគិលិ ឥសិគិលិ (ភ្នំលេបឥសី ៗ) ដូច្នេះ ។

**អាចិក្ខិស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់ឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ ។

**កិត្តយិស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងចង្អុលបង្ហាញឈ្មោះព្រះបច្ចកពុទ្ធទាំងឡាយ ។

**ទេសេស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ ។

**តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ** អ្នកទាំងឡាយចូរប្រុងស្តាប់នូវរឿងនោះចុះ ចូរធ្វើទុកក្នុងចិត្តឱ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។

**ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទាំងឡាយនោះក៏ទទួលឆ្លើយតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគដូច្នេះថា ភន្តេ បពិត្រព្រះអង្គដ៏ចម្រើន ។

**ភគវា ឯតទវោច** ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងយ៉ាងនេះថា

**អរិដ្ឋោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះអរិដ្ឋៈ បាន នៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**ឧបរិដ្ឋោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះឧបរិដ្ឋៈ បាន នៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**តគរសិខី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះតគរសិខី បាន នៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**យសស្សី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះយសស្សី បាន នៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**សុទស្សនោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះសុទស្សនៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**បិយទស្សី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះបិយទស្សី បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**គន្ធារោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះគន្ធារៈ បាន*

*នៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**បិណ្ឌោលោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះ បិណ្ឌោលៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**ឧបាសភោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះ ឧបាសភៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**នីថោ**[១] **នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះនិថៈ*[២] *បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**តថោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះតថៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**សុតវា នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះសុតវា បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**ភាវិតត្តោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះភាវិតត្តៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។*

**យេ សត្តសារា អនីឃា និរាសា**

**បច្ចេកមេវជ្ឈគមុំ[១] ពោធឹ**

**តេសំ វិសល្លាន នរុត្តមានំ**

**នាមានិ មេ កិត្តយតោ សុណាថ ។**

*ព្រះបច្ចេកពុទ្ធទាំងឡាយណា ជាខ្លឹមរបស់សត្វ អស់ទុក្ខ អស់ចំណង់ បានត្រាស់ដឹងហើយនូវបច្ចេកសុពោធិញ្ញាណ កាលបើតថាគតសម្តែងឈ្មោះរបស់ព្រះបច្ចេកពុទ្ធទាំងនោះ ដែលមានសរដេកចេញហើយ ដ៏ឧត្តមជាងជន អ្នកទាំងឡាយចូរស្តាប់ចុះ ។*

**អរិដ្ឋោ ឧបរិដ្ឋោ តគរសិខី យសស្សី**

**សុទស្សនោ បិយទស្សី ចពុទ្ធោ[២]**

**គន្ធារោ បិណ្ឌោលោ ឧបាសភោ ច**

**នីថោ តថោ[៣] សុតវា ភាវិតត្តោ ។**

**សុម្ភោ សុភោ មេថុលោ[៤] អដ្ឋមោ ច**

**អថស្សុមេឃោ អនីឃោ សុទាឋោ**

**បច្ចេកពុទ្ធា ភវនេត្តិខីណា**

**ហិង្គុ ច ហិង្គោ ច មហានុភាវា ។**

*ព្រះបច្ចេកពុទ្ធទាំងឡាយ ឈ្មោះអរិដ្ឋៈ ១ ឧបរិដ្ឋៈ ១ តគរសិខី ១ យសស្សី ១ សុទស្សនៈ ១ បច្ចេកពុទ្ធឈ្មោះ បិយទស្សី ១ គន្ធារៈ ១ បិណ្ឌោលៈ ១ ឧបាសភៈ ១ និថៈ ១ តថៈ ១ សុតវា ១ ភាវិតត្តៈ ១ សុម្ភៈ ១ សុភៈ ១ មេថុលៈ ១ អដ្ឋមៈ ១*

---

១-បាលីឆដ្ឋសង្គាយនាថា **គមំសុ**។ ២-បាលីឆដ្ឋសង្គាយនាថា **សុសម្ពុទ្ធោ**។ ៣-បាលីឆដ្ឋសង្គាយនាថា **នីតោ តថោ**។ ៤-បាលីឆដ្ឋសង្គាយនាថា **មតុលោ** ។

អស្សុមេឃ: ១ អនិឃ: ១ សុទាឋ: ១ ជាបច្ចេកពុទ្ធមានតណ្ហានាំទៅកាន់ភពអស់ហើយ ព្រះបច្ចេកពុទ្ធឈ្មោះ ហិង្គុ ១ ហិង្គ: ១ មានអានុភាពច្រើន ។

**ទ្វេ ជាលិនោ មុសិនោ អដ្ឋកោ ច**
**អថ កោសល្លោ ពុទ្ធោ អថោ សុពាហុ**
**ឧបនេមិសោ នេមិសោ សន្តចិត្តោ**
**សច្ចោ តថោ វិរជោ បណ្ឌិតោ ច ។**

ព្រះបច្ចេកពុទ្ធឈ្មោះជាលី ២ គឺចុល្លជាលី ១ មហាជាលី ១ ជាអ្នកប្រាជ្ញឈ្មោះអដ្ឋក: ១ ព្រះបច្ចេកពុទ្ធឈ្មោះ កោសល្ល: ១ សុពាហុ ១ ឧបនេមិស: ១ នេមិស: ១ សន្តចិត្ត: ១ សច្ច: ១ តថ: ១ វិរជ: ១ បណ្ឌិត: ១ ។

**កាឡូបកាឡា វិជិតោ ជិតោ ច**
**អង្គោ ច បង្គោ ច គុតិច្ឆិតោ ច**[១]
**បស្សិ ជហិ ឧបធិទុក្ខមូលំ**
**អបរាជិតោ មារពលំ អជេសិ ។**

ព្រះបច្ចេកពុទ្ធឈ្មោះ កាឡ: ១ ឧបកាឡ: ១ វិជិត: ១ ជិត: ១ អង្គ:១ បង្គ: ១ គុតិច្ឆិត: ១ ព្រះបច្ចេកពុទ្ធឈ្មោះ បស្សី ១ បានលះបង់ឧបធិកិលេស ជាឫសនៃសេចក្តីទុក្ខហើយ ព្រះបច្ចេកពុទ្ធឈ្មោះ អបរាជិត: បានផ្ចាញ់នូវមារនិងពលនៃមារហើយ ។

**សត្ថា បវត្តា សរភង្គោ លោមហំសោ**
**ឧច្ចង្គមាយោ អសិតោ អនាសវោ**
**មនោមយោ មានច្ឆិទោ ចពន្ធុមា**

---

១.បាលីឆដ្ឋសង្គាយនាថា **គុត្តិជិតោ ច** តែវចនានុក្រមព្រះត្រៃបិដកថា **គុត្តិជ្ជិត ច** ។

**តទាធិមុត្តោ វិមលោ ច កេតុមា ។**

ព្រះបច្ចេកពុទ្ធឈ្មោះ សត្ថា ១ បវត្តា ១ សរភង្គៈ ១ លោមហង្សៈ ១ ឧច្ចង្គមាយៈ ១ អសិតៈ ១ អនាសវៈ ១ មនោមយៈ ១ ពន្ធុមា ជាអ្នកផ្តាច់បង់នូវមានះ ១ ឈ្មោះតទាធិមុត្តៈ ១ វិមលៈ ១ កេតុមា ១ ។

**កេតុម្ភរាគោ ច មាតង្គោ អរិយោ**
**អថច្ចុតោ អច្ចុតគាមព្យាមកោ**
**សុមង្គលោ ទព្ពិលោ សុបតិដ្ឋិតោ**
**អសយ្ហោខេមាភិរតោ ច សោរតោ ។**
**ធុរន្ធយោ សង្ឃោ អថោបិ ឧជ្ជយោ**
**អបរោ មុនិ សយ្ហោ អនោមនិក្ខមោ**
**អានន្ទនន្ទោ**[១] **ឧបនន្ទោ ទ្វាទស**
**ភារទ្វាជោ អន្តិមទេហធារី ។**
**ពោធិ មហានាមោ អថោបិ ឧត្តរោ**
**កេសី សិខី សុន្ទរោ ទ្វារភាជោ**
**តិស្សូបតិស្សា ភវពន្ធនច្ឆិទា**
**ឧបសិខិ តណ្ហច្ឆិទោ ច សិខរី ។**

ព្រះបច្ចេកពុទ្ធឈ្មោះ កេតុម្ភរាគៈ ១ មាតង្គៈ ១ អរិយៈ ១ អថច្ចុត ១ អច្ចុតគាមព្យាមកៈ ១ សុមង្គលៈ ១ ទព្ពិលៈ ១ សុបតិដ្ឋិតៈ ១ អសយ្ហៈ ១ ខេមាភិរតៈ ១ សោរតៈ ១ ទុរន្ធយៈ ១ សង្ឃៈ ១ ឧជ្ជយៈ ១ និងបច្ចេកពុទ្ធដទៃទៀតឈ្មោះ សយ្ហៈ ជាអ្នកប្រាជ្ញ មានសេចក្តីព្យាយាមមិនថោកថយ ១ ព្រះបច្ចេកពុទ្ធ ១២ អង្គទៀត

---

១-បាលីឆដ្ឋសង្គាយនាថា **អានន្ទោ នន្ទោ** ។

ឈ្មោះ អានន្ទ: (៤ អង្គ) នន្ទ: (៤ អង្គ) ឧបនន្ទ: (៤ អង្គ) ភារទ្វាជ: ជាអ្នកទ្រទ្រង់នូវរាងកាយមានក្នុងទីបំផុតភព ១ ពោធិ ១ មហានាម: ១ ឧត្តរ: ១ កេសី ១ សិខី ១ សុន្ទរ: ១ ភារទ្វាជ: ១ តិស្ស: ១ ឧបតិស្ស: ១ ជាអ្នកផ្តាច់បង់នូវចំណង់គឺភព ឈ្មោះ ឧបសីទរី ១ សីទរី ជាអ្នកផ្តាច់បង់តណ្ហា ១ ។

**ពុទ្ធោ អហុ មង្គលោ វីតរាគោ**
**ឧសភច្ឆិទា ជាលិនី ទុក្ខមូលំ**
**សន្តិំ បទំ អជ្ឈគមោបនីតោ**
**ឧបោសថោ សុន្ទរោ សច្ចនាមោ ។**

បច្ចេកពុទ្ធឈ្មោះ មង្គល: មានរាគៈទៅប្រាស់ហើយ ១ ឈ្មោះឧសភ: បានផ្តាច់បង់នូវតណ្ហា ជាឫសនៃទុក្ខ ១ ឧបណីត: បានដល់នូវចំណែកស្ងប់រំងាប់ ១ ឧបោសថ: ១ សុន្ទរ: ១ សច្ចនាម: ១ ។

**ជេតោ ជយន្តោ បទុមោ ឧប្បលោ ច**
**បទុមុត្តរោ រក្ខិតោ បព្វតោ ច**
**មានត្ថទ្ធោ សោភិតោ វីតរាគោ**
**កណ្ហោ ច ពុទ្ធោ សុវិមុត្តចិត្តោ ។**

បច្ចេកពុទ្ធឈ្មោះ ជេត: ១ ជយន្ត: ១ បទុម: ១ ឧប្បល: ១ បទុមុត្តរ: ១ រក្ខិត: ១ បព្វត: ១ មានត្ថទ្ធ: ១ សោភិត: ១ វីតរាគ: ១ កណ្ហ: ១ បានត្រាស់ដឹងហើយ មានចិត្តរួចវិសេសហើយ ។

**ឯតេ ច អញ្ញេ ច មហានុភាវា**
**បច្ចេកពុទ្ធា ភវនេត្តិខីណា**
**តេ សព្វសង្គាតិគតេ មហេសី**

**បរិនិព្វុតេ ឧន្នថ អប្បមេយ្យេតិ ។**

ព្រះបច្ចេកពុទ្ធមានឈ្មោះប៉ុណ្ណេះ និងនៅមានឈ្មោះដទៃទៀត មាន អានុភាពច្រើន មានតណ្ហាជាគ្រឿងនាំទៅកាន់ភពអស់ហើយ អ្នកទាំងឡាយ ចូរថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធទាំងឡាយនោះ ដែលកន្លងនូវកិលេសជាគ្រឿង ជាប់ចំពាក់ទាំងពួង ស្វែងរកនូវគុណដ៏ប្រសើរ មានគុណរកប្រមាណមិនបាន ដែលបរិនិព្វានទៅហើយ ។

**ឥសិគិលិសុត្តំ និដ្ឋិតំ**

*ឥសិគិលិសូត្រ ចប់*

## ចប់ ព្រះបរិត្តតែប៉ុណ្ណេះ

# អ ដ្ឋ ក ថា

## ឥសិគិលិសូត្រទី ៦

[២៨៧] *ឥសិគិលិសូត្រ* មានពាក្យផ្ដើមថា ***ឯវំមេ សុតំ*** ខ្ញុំបានស្ដាប់មកហើយដូច្នេះ ។

### *ប្រវត្តិភ្នំឥសិគិលិ*

គប្បីជ្រាបអធិប្បាយក្នុងឥសិគិលិសូត្រនោះ ដូចតទៅនេះ ៖

[២៨៨] បទថា ***អញ្ញាវ សមញ្ញា អហោសិ*** សេចក្ដីថា (មុន) ដែលភ្នំឥសិគិលិនឹងបានឈ្មោះថា ***ឥសិគិលិ*** (នោះ) មានឈ្មោះម្យ៉ាងទៀតថា ***វេភារៈ*** ។

បទថា ***អញ្ញា បញ្ញត្តិ*** នេះ ជាវេវចនៈរបស់បទដំបូងប៉ុណ្ណោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បានឮថា គ្រាមុននោះ ព្រះមានព្រះភាគទ្រង់ចេញចាកនិរោធសមាបត្តិក្នុងវេលាល្ងាច ហើយស្ដេចចេញចាកព្រះគន្ធកុដិ មានពួកភិក្ខុហែហមប្រថាប់គង់ក្នុងទីដែលមនុស្សទាំងឡាយអង្គុយហើយ ឃើញកូនភ្នំទាំង ៥ ប្រាកដច្បាស់ហើយត្រាស់ប្រាប់កូនភ្នំ ៥ ទាំងនេះដោយលំដាប់ ។ ក្នុងការត្រាស់ប្រាប់នោះ

ព្រះមានព្រះភាគ ទ្រង់មិនមានសេចក្តីត្រូវការដោយរឿងភ្នំ ។ តែកាលត្រាស់ប្រាប់ភ្នំទាំងនោះដោយលំដាប់ៗ ទ្រង់ក៏ត្រាស់ប្រាប់ភាវៈនៃភ្នំឥសិគិលិ ជាភ្នំ (មានឈ្មោះថា) **ឥសិគិលិ** ផង ។ កាលត្រាស់ប្រាប់រឿងភ្នំឥសិគិលិនោះ ក៏ទីងត្រូវត្រាស់ប្រាប់ឈ្មោះរបស់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដែលជាបុត្ររបស់នាងបទុមវតី និងសេចក្តីប្រាថ្នារបស់នាងបទុមវតី ព្រោះហេតុដូចពោលមកនេះ ព្រះមានព្រះភាគទើបត្រាស់លំដាប់របស់ភ្នំនេះ ។

[២៤៩] បទថា **បវិសន្តា ទិស្សន្តិ បវិដ្ឋា ន ទិស្សន្តិ** សេចក្តីថា ព្រះបច្ចេកពុទ្ធទាំងឡាយ ត្រាច់បិណ្ឌបាតក្នុងស្ថានទីតាមសប្បាយ ធ្វើភត្តកិច្ចស្រេចហើយ ចូលទៅខាងក្នុងដោយធ្វើភ្នំនោះឲ្យជា ២ ចំណែក ដូចបើកទ្វារធំមួយគូ ក្នុងបន្ទប់ព្រះចេតិយ សាងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ហើយនៅក្នុងទីនោះ ។ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។

បទថា **ឥមេ ឥសី** បានដល់ ឥសីដែលជាព្រះបច្ចេកពុទ្ធទាំងនេះ ។

បានឮថា ក្នុងអតីតកាល កាលព្រះតថាគតមិនទាន់ឧប្បត្តិឡើង កុលធីតាម្នាក់ក្នុងស្រុកមួយកន្ទែងជាយក្រុងពារាណសី នៅចាំស្រែ បានថ្វាយផ្កាឈូកមួយទង និងលាជ ៥០០ គ្រាប់ ដល់ព្រះបច្ចេកពុទ្ធមួយអង្គ តាំងសេចក្តីប្រាថ្នា

ឲ្យបានបុត្រ ៥០០ នាក់ ។ ក៏ព្រមគ្នានឹងខណៈនោះ ព្រានម្រឹគ ៥០០ នាក់ បានថ្វាយសាច់ (អាំង) ដ៏ឆ្ងាញ់ ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យពួកយើងបានជាបុត្ររបស់នាង ។ នាងស្ថិតនៅរហូតអស់កាលកំណត់អាយុ ហើយទៅកើតក្នុងទេវលោក ចុតិអំពីទេវលោក មកកើតក្នុងត្របកផ្កាឈូកក្នុងជាតស្រះ (ស្រះដែលកើតឯងដោយធម្មជាតិ) ។ ព្រះតាបសមួយអង្គទៅជួបទារិកានោះ ក៏យកមកចិញ្ចឹម ។ កាលនាងកំពុងរត់លេងទុំះឯង ផ្កាឈូកទាំងឡាយផុសឡើងអំពីផែនដី គ្រប់ៗ ជំហាន ។ ព្រានព្រៃម្នាក់ឃើញ ទើបក្រាបទូលដល់ព្រះបាទពារាណសី ។ ព្រះរាជាទ្រង់នាំនាងមក តាំងក្នុងតំណែងជាអគ្គមហេសី ។ ព្រះនាងទ្រង់គភ៌ ។ មហាបទុមកុមារនៅក្នុងព្រះគភ៌ព្រះមាតា ចំណែកកុមារក្រៅពីនោះអាស្រ័យមន្ទិលរបស់គភ៌ឧប្បត្តិឡើង ។ កុមារទាំងនោះចម្រើនវ័យបានលេងក្នុងស្រះឈូកក្នុងឧទ្យាន អង្គុយលើផ្កាឈូកម្នាក់មួយផ្កា ផ្តើមការអស់ទៅ និងការសាបសូន្យ ធ្វើបច្ចេកពោធិញ្ញាណឲ្យកើតឡើង គាថាព្យាករណ៍របស់លោកមានដូច្នេះថា

ផ្កាឈូកក្នុងគុម្ពឈូកកើតឡើងក្នុងស្រះ រីកហើយ ត្រូវពួកភមរជាតិក្រេបហើយ ក៏ចូលដល់សេចក្តីរុះរោយ បុគ្គលដឹង

ច្បាស់ប្រការនេះហើយ គប្បីជាអ្នកត្រាច់ទៅតែម្នាក់ឯង ដូច

កុយរមាស ។

ព្រះបច្ចេកពុទ្ធទាំងឡាយនោះ បានទៅក្នុងភ្នំនោះ តាំងពីកាលនោះ ។ តាំងពីពេលនោះមក ភ្នំនោះ ទើបមានឈ្មោះថា **ឥសិគិលិ** ។

## ព្រះនាមរបស់ព្រះបច្ចេកពុទ្ធ

**[២៥០]** បទថា ***យេ សត្តសារា*** សេចក្តីថា ព្រះមានព្រះភាគត្រាស់ឈ្មោះរបស់ព្រះបច្ចេកពុទ្ធ ១៣ ព្រះអង្គ គឺ ព្រះអរិដ្ឋៈ ព្រះឧបរិដ្ឋៈ ព្រះតគ្គរសិខី ព្រះយសស្សី ព្រះសុទស្សនៈ ព្រះបិយទស្សី ព្រះគន្ធារៈ ព្រះបិណ្ឌោលៈ ព្រះឧបាសភៈ ព្រះនិថៈ ព្រះតថៈ ព្រះសុតវា ព្រះភាវិតត្តៈ ឥឡូវនេះកាលនឹងត្រាស់ប្រាប់ឈ្មោះរបស់ព្រះបច្ចេកពុទ្ធទាំងនោះ និងឈ្មោះរបស់ព្រះបច្ចេកពុទ្ធអង្គដទៃ ដោយការចងជាគាថា ទើបត្រាស់ពាក្យជាដើមថា ***យេ សត្តសារា*** ដូច្នេះ ។

**[២៥១]** ក្នុងព្រះនាមទាំងនោះ ព្រះនាមថា ***សត្តសារា*** ប្រែថា ជាខ្លឹមរបស់សត្វទាំងឡាយ ព្រះនាមថា ***អនីឃា*** ប្រែថា មិនមានទុក្ខ ។ ព្រះនាមថា ***និរាសា*** ប្រែថា មិនមានសេចក្តីប្រាថ្នា ។

ព្រះនាមថា **ទេ្វ ជាលិនោ** សេចក្តីថា ព្រះនាមថា **ជាលី** មាន ២ អង្គ គឺ **ចូឡជាលី** និង **មហាជាលី** ។ សូម្បីពាក្យថា **សន្តចិត្ត** ក៏ជាព្រះនាមរបស់ព្រះបច្ចេកពុទ្ធមួយអង្គ ។

បទថា **បស្សី ជហិ ឧបធី ទុក្ខមូលំ** នេះ ជាពាក្យសរសើរព្រះបច្ចេក-ពុទ្ធអង្គនោះថា ព្រះបច្ចេកពុទ្ធអង្គនោះ ទ្រង់ព្រះនាមថា **បស្សី** ក៏ព្រោះព្រះអង្គទ្រង់លះឧបធិ ដែលជាឫសគល់នៃទុក្ខបានហើយ ។

សូម្បីពាក្យថា **អបរាជិត** ក៏ជាឈ្មោះរបស់ព្រះបច្ចេកពុទ្ធមួយព្រះអង្គដូចគ្នា ។ លោកទាំង ៥ អង្គនេះ គឺ ព្រះសត្ថា ព្រះបវត្តា ព្រះសរភង្គៈ ព្រះលោមហង្សៈ ព្រះឧច្ចង្គមាយៈ ។ លោកទាំង ៣ អង្គសូម្បីទាំងនេះ គឺ ព្រះអសិតៈ ព្រះអនាសវៈ ព្រះអនោមយៈ ។

បទថា **ពន្ធុមា** សេចក្តីថា ព្រះបច្ចេកពុទ្ធមួយព្រះអង្គទ្រង់ព្រះនាមថា **ពន្ធុមា** ហៅថា **ព្រះមានច្ឆិទ** ព្រោះលោកកម្ចាត់មានះបានហើយ ។

សូម្បីបទថា **តទាធិមុត្ត** ក៏ជាព្រះនាមព្រះបច្ចេកពុទ្ធដូចគ្នា ។ លោកទាំង ៣ អង្គនេះ គឺ ព្រះកេតុម្ភរាគៈ ព្រះមាតង្គៈ ព្រះអរិយៈ ។

បទថា **អថច្ចុតោ** ចែកបទចេញជា **អថ អច្ចុតោ** គឺ ព្រះអច្ចុតៈ ។

លោកទាំងពីរនេះ គឺ ព្រះអច្ចុតៈ ព្រះអច្ចុតគាមព្យាមកៈ ។ លោកទាំងពីរអង្គនេះ គឺ ព្រះខេមកភិរៈ ព្រះសោរតៈ ។

បទថា ***សយ្ហោ អនោមនិក្កមោ*** សេចក្តីថា ព្រះបច្ចេកពុទ្ធអង្គនោះឈ្មោះសយ្ហៈ តែគេហៅថា អនោមនិក្កមៈ ព្រោះមានសេចក្តីព្យាយាមមិនធូរថយ ។

បទថា ***អានន្ទនន្ទោ ឧបនន្ទោ ទ្វាទស*** សេចក្តីថា ព្រះបច្ចេកពុទ្ធ ១២ អង្គ យ៉ាងនេះ គឺ ព្រះអានន្ទៈ ៤ អង្គ ព្រះនន្ទៈ ៤ អង្គ ព្រះឧបនន្ទៈ ៤ អង្គ ។

បទថា ***ភារទ្វាជោ អន្តិមទេហធារី*** ជាពាក្យសរសើរថា ព្រះបច្ចេកពុទ្ធអង្គនោះ ឈ្មោះភារទ្វាជៈ អ្នកទ្រទ្រង់ព្រះសរីរៈជាគ្រាចុងក្រោយ ។

បទថា ***តណ្ហច្ឆិទោ*** បានដល់ នេះជាពាក្យសរសើរព្រះបសីទរី សូម្បីបទថា ***វីតរាគោ*** ក៏ជាពាក្យសរសើរព្រះមន្តលៈ ។

បទថា ***ឧសភច្ឆិទា ជាលិនី ទុក្ខមូលំ*** សេចក្តីថា ព្រះពុទ្ធអង្គនោះឈ្មោះឧសភៈ បានកាត់នូវសំណាញ់ គឺ តណ្ហាដែលជាឫសគល់នៃទុក្ខបានហើយ ។

បទថា ***សន្តំ បទំ អជ្ឈគមូបនីតោ*** សេចក្តីថា ព្រះបច្ចេកពុទ្ធព្រះអង្គនោះ ឈ្មោះឧបនីយៈ បានសម្រេចសន្តិបទហើយ ។ សូម្បីបទថា ***វីតរាគ*** ក៏ជាព្រះនាមរបស់ព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដូចគ្នា ។

បទថា ***សុវិមុត្តចិត្តោ*** បានដល់ នេះជាពាក្យសរសើរព្រះកណ្ហៈ ។

បទថា ***ឯតេ ច អញ្ញេ ច*** សេចក្ដីថា ព្រះបច្ចេកពុទ្ធទាំងឡាយនេះទាំងដែលមកក្នុងព្រះបាលី និងមិនបានមកក្នុងព្រះបាលី និងព្រះបច្ចេកពុទ្ធពួកដទៃ ព្រះបច្ចេកពុទ្ធទាំងនេះ មានព្រះនាមតែម្យ៉ាងប៉ុណ្ណោះ ។

ក៏បណ្ដាព្រះបច្ចេកពុទ្ធ ៥០០ ទាំងនេះ ព្រះបច្ចេកពុទ្ធ ២ អង្គក្ដី ៣ អង្គក្ដី ១០ អង្គក្ដី ១២ អង្គក្ដី មានព្រះនាមតែម្យ៉ាងគ្នា ដូចព្រះបច្ចេកពុទ្ធទាំងឡាយមានព្រះអានន្ទៈ ជាដើម ។

ដោយប្រការដូចពោលនេះ រមែងជាការសរុបព្រះនាមរបស់ព្រះបច្ចេក-ពុទ្ធទាំងឡាយ ដោយព្រះនាមដែលមកក្នុងព្រះបាលីប៉ុណ្ណោះ ព្រោះហេតុនោះតអំពីនេះទៅ មិនត្រាស់ចែកជាកាយអន្ត ត្រាស់ (រួម) ថា ពួកទាំងនេះ និងពួកដទៃ ដូច្នេះ ។ ពាក្យនៅសល់ក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។

**ចប់អដ្ឋកថា ឥសិគិលិសូត្រទី ៦**